# សេចក្តីសង្ខេប ប្រតិបត្តិ

**ផ្នែក**

**អនាគតដែលធន់ និងគ្មានផូស៊ីល**

**របៀបដែលយើងបង្កើតផែនការ**

**អ្វីដែលយើងតម្រង់គោលដៅដើម្បីសម្រេចបាន**

**របៀបដែលយើងរៀបរចនាសម្ព័ន្ធផែនការ**

**របៀបដែលយើងនឹងអនុវត្ត និង វាយតម្លៃផែនការ**

**សន្និដ្ឋាន**



ផែនការនេះ រួមជាមួយផែនការផ្សេងទៀតនៅក្នុងតំបន់ នឹងជួយរក្សាសហគមន៍របស់យើងឲ្យមានសុវត្ថិភាព និងរួមចំណែកដល់គោលដៅកាត់បន្ថយកាបូនកម្រិតជាតិ និងកម្រិតសាកល។

Alameda County
**SUSTAINABILITY**
*Local Action, Global Impact.*

វិចិត្រករ៖ ហ៊ីលដា ស៊ី. រ៉ូប៊ីនស៊ុន ។ ចំណងជើង៖ នៅក្នុងភូមិសង្កាត់។ ពីកម្រងសិល្បៈខោនធី អាឡាមេដា។ រក្សាសិទ្ធិវិចិត្រករ។

# អនាគតដែលធន់ និងគ្មានផូស៊ីល

អ្នកវិទ្យាសាស្ត្របានព្រមានជាយូរមកហើយអំពីគ្រោះថ្នាក់នៃការប្រែប្រួលអាកាសធាតុ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ បញ្ហាទាំងនេះមិនអាចឱ្យសហគមន៍ និងតំបន់របស់យើងព្រងើយកន្តើយបានឡើយ៖ ផ្ទៃមេឃពណ៌ទឹកក្រូចដ៏គួរឱ្យខ្លាច និងគុណភាពខ្យល់ដែលមានគ្រោះថ្នាក់ដែលបង្កដោយផ្សែងចេញពីការឆេះព្រៃដែលមិនអាចគ្រប់គ្រងបាន កម្ដៅក្ដៅខ្លាំងហួសហេតុធ្វើឱ្យសុខភាពដែលមានបញ្ហាស្រាប់កាន់តែមានសភាពធ្ងន់ធ្ងរ ជាពិសេសចំពោះមនុស្សចាស់ និងកុមារតូចៗ។ គ្រោះរាំងស្ងួតច្រើនឆ្នាំរួមផ្សំជាមួយទឹកជំនន់ពីគន្លងផ្លូវទឹកបន្តបន្ទាប់គ្នានៅក្នុងបរិយាកាសបានបង្ហាញពីអ្វីដែលការប្រែប្រួលអាកាសធាតុខ្លាំងអាចបង្កឡើង។ គេរំពឹងថាព្រឹត្តិការណ៍ដ៏គ្រោះថ្នាក់ទាំងនេះនឹងកាន់តែមានញឹកញាប់ជាធម្មតា។

ផែនការសកម្មភាពខាងអាកាសធាតុនេះគឺផ្អែកលើវឌ្ឍភាពពីមុនរបស់យើង។ ខោនធី អាឡាមេដា ទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុដ៏គំរាមកំហែងធ្វើឲ្យមានការប្ដេជ្ញាចំពោះសកម្មភាពជាផ្លូវការលើកទីមួយរបស់យើងនៅឆ្នាំ 2006។ ពីមុន ខោនធីបានអនុម័តផែនការសកម្មភាពខាងអាកាសធាតុចំនួនពីរ៖ ផែនការមួយផ្ដោតលើប្រតិបត្តិការ និងសេវាកម្មរបស់យើងនៅឆ្នាំ 2010 ហើយផែនការមួយទៀតផ្ដោតលើសហគមន៍មិនរួមបញ្ចូលរបស់យើងនៅឆ្នាំ 2014។ (សូមមើលផែនការទាំងនេះ [នៅទីនេះ។]) ផែនការរបស់យើងគឺជាឧបករណ៍គោលនយោបាយដែលបង្កើតនូវរបៀបដែលយើងគ្រោងនឹងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងឆ្លើយតបនឹងផលប៉ះពាល់នៃអាកាសធាតុដែលពាក់ព័ន្ធ។

តាមការណែនាំពីផែនការនេះ យើងនឹងវិនិយោគលើការផ្ដល់សេវាកម្មដែលមានភាពធន់ ហើយបន្តកាត់បន្ថយការបំភាយឧស្ម័នយ៉ាងខ្លាំងក្លានៅក្នុងប្រតិបត្តិការរបស់ខោនធី។ យើងទន្ទឹងរង់ចាំក្នុងការគាំទ្រនិងការសហការជាមួយសហគមន៍ និងក្រុមនានាដែលបានរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុរួចហើយ។ សហគមន៍រាប់ពាន់នៅទូទាំងប្រទេសកំពុងធ្វើសកម្មភាព ហើយយើងមានមោទនភាពក្នុងការចូលរួមជាមួយពួកគេ។

ផែនការសកម្មភាពខាងអាកាសធាតុរបស់យើងសម្រាប់សេវាកម្ម និងប្រតិបត្តិការរបស់រដ្ឋាភិបាលរហូតដល់ឆ្នាំ 2020 បានអនុម័តនៅឆ្នាំ 2010 បានត្រួសត្រាយផ្លូវដើម្បីឱ្យប្រតិបត្តិការរបស់ខោនធីសម្រេចបាននូវការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់អប្បបរមា 15 ភាគរយ និងគោលដៅពង្រីក 30 ភាគរយត្រឹមឆ្នាំ 2020 ពីបន្ទាត់គោលឆ្នាំ 2003។ ផែនការនេះក៏បានកំណត់គោលដៅរយៈពេលវែងកាត់បន្ថយការបំភាយឧស្ម័ន 80 ភាគរយត្រឹមឆ្នាំ 2050 ដែរ។ កិច្ចខិតខំប្រឹងប្រែងរបស់យើងបានលើសគោលដៅពង្រីក ឆ្នាំ 2020៖ យើងសម្រេចបានការកាត់បន្ថយ 31 ភាគរយលើការបំភាយឧស្ម័នពីប្រតិបត្តិការ។

ផែនការសកម្មភាពខាងអាកាសធាតុថ្មីនេះកំណត់គោលដៅសម្រាប់ប្រតិបត្តិការនិងសេវាកម្មរបស់ខោនធីដែលលើសគោលដៅឆ្នាំ 2050 ពីមុនរបស់យើង និងស្របជាមួយនឹងគោលដៅរបស់រដ្ឋ កាលីហ្វ័រញ៉ាស្តីពីការបន្សាបកាបូនត្រឹមឆ្នាំ 2045។ វាបង្កើតជាជំហានបន្តបន្ទាប់ដែលខោនធីត្រូវអនុវត្តចន្លោះឆ្នាំ 2023 និង 2026 ដើម្បីនាំយើងឆ្ពោះទៅរកគោលដៅនោះ។ ហើយវាបង្កើតជាសំណុំនៃសកម្មភាពដើម្បីការពារសហគមន៍របស់យើងពីផលប៉ះពាល់នៃអាកាសធាតុ និងការពារទ្រព្យសម្បត្តិ និងសេវាកម្មរបស់ខោនធីដែលសំខាន់សម្រាប់បម្រើសាធារណជន។

សកម្មភាពខាងអាកាសធាតុគឺស្របជាមួយផែនការយុទ្ធសាស្ត្ររបស់ខោនធី។ ចក្ខុវិស័យឆ្នាំ 2026ចក្ខុវិស័យរបស់ខោនធីដើម្បីប្រមើលមើលបញ្ហាប្រឈមរបស់សហគមន៍ និងឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនមូលដ្ឋាន ត្រូវបានអនុម័តនៅឆ្នាំ 2018 និងផ្តល់គោលដៅ និងគោលការណ៍ណែនាំសម្រាប់ការងារខោនធីរហូតដល់ឆ្នាំ 2026។ វាមានធាតុផ្សំនានានៃចក្ខុវិស័យចំនួនបួនគឺ—បរិស្ថានមានសុខភាពល្អ សហគមន៍មានសុវត្ថិភាពនិងអាចរស់នៅបាន ប្រជាជនរីកចម្រើននិងមានភាពធន់ ហើយនិងសេដ្ឋកិច្ចរស់រវើកនិងមានវិបុលភាព—ដែលទាំងអស់នោះសុទ្ធតែមានការគាំទ្រពីសកម្មភាពខាងអាកាសធាតុ។

## របៀបដែលយើងបង្កើតផែនការ

យើងបានចាប់ផ្តើមធ្វើការលើផែនការនេះដោយមានការវាយតម្លៃបន្ទាត់គោលនៃការបំភាយឧស្ម័នពីខ្សែសង្វាក់ផ្គត់ផ្គង់ និងពីប្រតិបត្តិការរបស់យើង។ ផែនការចុងក្រោយផ្តោតច្រើនលើការកាត់បន្ថយការបំភាយឧស្ម័ន ហើយជាផែនការដែលមានរយៈពេល 10 ឆ្នាំ។ ភ្លាមៗនោះយើងដឹងថាយើងត្រូវអនុវត្តវិធីសាស្ត្រផ្សេងសម្រាប់ផែនការនេះ។ យើងបានសម្រេចចិត្តលើរយៈពេលកំណត់បួនឆ្នាំ ដែលស្របនឹងការធ្វើបច្ចុប្បន្នភាពចក្ខុវិស័យឆ្នាំ 2026 នៅឆ្នាំ 2026។ ដោយសារតំបន់ឈូងសមុទ្របានរងការខូចខាតដោយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ រួមមានរលកកម្តៅ និងព្យុះធ្ងន់ធ្ងរ វាកាន់តែច្បាស់ហើយថាយើងមិនត្រឹមតែត្រូវគិតពីការកាត់បន្ថយការបំភាយឧស្ម័ននាពេលអនាគតទេ ប៉ុន្តែក៏ត្រូវគិតអំពីការកាត់បន្ថយឥទ្ធិពលដែលមានស្រាប់ផងដែរ។ ការរាតត្បាតជាសាកលនៃជំងឺកូវីដ-19 បានរំលេចឱ្យឃើញនូវវិសមធម៌ដែលមានស្រាប់នៅក្នុងខោនធី និងតម្រូវការក្នុងការផ្តល់អាទិភាពដល់ផ្នែកសមធម៌នៅក្នុងដំណើរការរៀបផែនការរបស់យើង។




### សមធម៌

ខោនធីប្តេជ្ញាដោះស្រាយបញ្ហាអយុត្តិធម៌ប្រកាន់ពូជសាសន៍ និងវិសមធម៌ផ្នែកសុខភាព និងសង្គមផ្សេងទៀត។ ដើម្បីជួយបង្កើតវិធានការ និងអាទិភាព យើងបានធ្វើការជាដៃគូជាមួយក្រុមហ៊ុនពិគ្រោះសាយោបល់ផ្នែកផែនការអាកាសធាតុដែលមានបទពិសោធន៍ ដែលជាអ្នកពិគ្រោះសាយោបល់ផ្នែកសមធម៌ក្នុងមូលដ្ឋាន និងអង្គការសហគមន៍នានាដើម្បីកោះប្រជុំក្រុម

ផ្តោត កោះប្រជុំវគ្គស្តាប់យោបល់ និងការស្ទង់មតិតាមផ្ទះជាមួយនឹងសមាជិកសហគមន៍ជួរមុខ—ក្រុមដែលរងបន្ទុកដោយគ្មានសមាមាត្រគ្នានាដោយសារការប្រែប្រួលអាកាសធាតុ—ដើម្បីយល់និងរួមបញ្ចូលតម្រូវការ អាទិភាព និងកង្វល់របស់ពួកគេ។ ក្រុមការងារគម្រោងនៃនិយោជិតខោនធីក៏ត្រួតពិនិត្យឡើងវិញនូវវិធានការនានាដោយប្រើ ឧបករណ៍ពង្រីកសមធម៌សាកល្បងផងដែរ ដែលជាសន្លឹកកិច្ចការដែលមានសំណួរអំពីឥទ្ធិពលសមធម៌នៃវិធានការពង្រាងផ្នែកអាកាសធាតុ។

### ការផ្សព្វផ្សាយជាសាធារណៈ និងការចូលរួមរបស់បុគ្គលិក

បន្ថែមលើការផ្សព្វផ្សាយរបស់យើងដល់សហគមន៍ជួរមុខ យើងបានធ្វើការស្ទង់មតិជាសាធារណៈតាមអនឡាញ រៀបចំសិក្ខាសាលា និងបង្កើតវេទិកាមតិត្រលប់តាមអនឡាញចំនួនពីរសម្រាប់ឱ្យប្រជាជនក្នុងមូលដ្ឋានរបស់យើងចែករំលែកអាទិភាព និងកង្វល់របស់ពួកគេ។ ឯកសារជាលាយលក្ខណ៍អក្សរ ដូចជាឯកសារស្ទង់មតិ គឺមានជាភាសាអង់គ្លេស ចិនបុរាណ និងអេស្ប៉ាញ ហើយគេផ្តល់ជូនការបកប្រែសម្រាប់សិក្ខាសាលា។

ផែនការនេះធ្វើឱ្យខោនធីដើរឆ្ពោះទៅរកគោលដៅបន្សាបកាបូនសម្រាប់ប្រតិបត្តិការ និងសេវាកម្មរបស់រដ្ឋាភិបាលត្រឹមឆ្នាំ 2045។

ការងារផ្ទៃក្នុងអំពីផែនការគឺដឹកនាំដោយក្រុមអភិវឌ្ឍន៍សកម្មភាពខាងអាកាសធាតុ ដែលមានបុគ្គលិកចំនួនជាង 30 នាក់មកពីទីភ្នាក់ងារចំនួន 10។ ក្រុមនេះកំណត់ទិសដៅយុទ្ធសាស្ត្រ និងជួយនៅក្នុងការអភិវឌ្ឍផែនការក្នុងនាមជាអ្នកគ្រប់គ្រង និងអ្នកអនុវត្តសកម្មភាពខាងអាកាសធាតុតាមតួនាទីរៀងៗខ្លួន។ មេក្រុមខោនធីសម្រាប់វិស័យសកម្មភាពខាងអាកាសធាតុ ដូចជាបរិស្ថានដែលត្រូវបានបង្កើតឡើង ឬការដឹកជញ្ជូនធ្វើដំណើរ បានពិគ្រោះយោបល់បុគ្គលិកជាប្រចាំដែលនឹងអនុវត្តវិធានការ ឬមានជំនាញពាក់ព័ន្ធនឹងវិស័យទាំងនោះ។ យើងក៏បានអញ្ជើញនិយោជិតរបស់ខោនធីឱ្យចូលរួមចំណែកនៅលើការពិភាក្សាលើផែនការតាមរយៈការស្ទង់មតិនិយោជិតអំពីអាកាសធាតុ។

## អ្វីដែលយើងតម្រង់គោលដៅដើម្បីសម្រេចបាន

ផែនការនេះធ្វើឱ្យខោនធីដើរឆ្ពោះទៅរកគោលដៅបន្សាបកាបូនសម្រាប់ប្រតិបត្តិការ និងសេវាកម្មរបស់រដ្ឋាភិបាលត្រឹមឆ្នាំ 2045។ ការបន្សាបអាកាសធាតុមានន័យថាការលុបបំបាត់បរិមាណបំភាយឧស្ម័នផ្ទះកញ្ចក់ដែលយើងផលិតលើសពីអ្វីដែលភពផែនដីបំបាត់ចេញតាមធម្មជាតិ វាទាមទារឱ្យមានការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើន។ ដើម្បីសម្រេចបាននូវគោលដៅនេះ ខោនធីត្រូវ៖

- ពង្រីកការងារចល័ត និងការនាំមកជូននូវសេវាកម្មនិម្មិតជាអាទិភាព ដែលកាត់បន្ថយតម្រូវការដែលនិយោជិត និងអតិថិជនរបស់ខោនធីធ្វើដំណើរទៅមកពីកន្លែងធ្វើការ ឬដើម្បីធ្វើដំណើរទៅទទួលសេវាកម្ម។
- បង្រួមចូលគ្នានូវតម្រូវការទីលំហ និងប្រើប្រាស់ទីលំហដែលខោនធីកាន់កាប់ ទីលំហដែលខោនធីជួលឱ្យមានប្រសិទ្ធភាព ដើម្បីចៀសវាងការខ្ជះខ្ជាយធនធាន រួមមាន អគ្គិសនី ហ្គាស និងទឹក នៅលើទីកន្លែងដែលប្រើប្រាស់តិច។

- បញ្ចូលអគ្គិសនីដល់ឧបករណ៍សាងសង់របស់ខោនធី។
- បន្តទិញអគ្គិសនីកកើតឡើងវិញដែលមិនបំភាយកាបូនពីក្រុមហ៊ុនផ្គត់ផ្គង់ថាមពលក្នុងមូលដ្ឋាន។
- បញ្ចូលអគ្គិសនីដល់ក្រុមយានជំនិះរបស់ខោនធី និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសាកភ្លើងយានជំនិះអគ្គិសនី (EV)។
- បន្តប្រើប្រភពឥន្ធនៈកកើតឡើងវិញ ដូចជាប្រេងម៉ាស៊ូតកកើតឡើងវិញ សម្រាប់យានជំនិះនៅក្នុងក្រុមយានរបស់យើងដែលមិនទាន់មានជម្រើសអគ្គិសនីដែលអាចដំណើរការបាន។
- គាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចវិលជុំថ្នាក់តំបន់សម្រាប់ទំនិញ និងអាហារតាមរយៈសកម្មភាពប្រើប្រាស់ឡើងវិញ ជួសជុល ចែកចាយឡើងវិញ និងលទ្ធកម្ម។



*ស្នាដៃ៖ ស៊ីប៊ីឡា សារ៉ាហ្វេ*

លើសពីនេះ យើងមានបំណងអភិវឌ្ឍសេវាកម្មដែលមានភាពធន់ និងគាំទ្រភូមិសង្កាត់ដែលមានភាពធន់។ ខ្នាតវាស់វែងភាពធន់គឺមានស្តង់ដារកម្មចាញ់ខ្នាតវាស់វែងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដូច្នេះយើងនឹងត្រូវការបង្កើតវិធីសាស្ត្រដើម្បីវាស់វែងលទ្ធផលភាពធន់ដែលរងឥទ្ធិពលពីសកម្មភាពរបស់រដ្ឋាភិបាលខោនធី។ យើងដឹងថាដើម្បីជួយឱ្យសេវាកម្ម និងតំបន់របស់យើងកាន់តែមានភាពធន់ ខោនធីត្រូវ៖

- វិនិយោគលើការត្រៀមលក្ខណៈសម្រាប់ផលប៉ះពាល់ជាក់លាក់ដូចជា ភ្លើងឆេះព្រៃ ព្យុះ និងទឹកជំនន់។
- ផ្តល់ការបណ្តុះបណ្តាលអំពីវិធានការការពារដល់សាធារណជន ដល់និយោជិតរបស់ខោនធី និងដល់ដៃគូដែលមានមូលដ្ឋាននៅក្នុងសហគមន៍ ដូចជារបៀបត្រៀមខ្លួនចំពោះរលកកម្តៅ។
- បង្កើនលទ្ធភាពប្រើប្រាស់ធនធានសម្រាប់ការត្រៀមលក្ខណៈ និងព័ត៌មានក្នុងអំឡុងពេលគ្រោះអាសន្នតាមរយៈធ្វើឱ្យភាសា និងបណ្តាញទំនាក់ទំនងមានភាពសម្បូរបែប។
- ពង្រីកការគាំទ្រប្រជាជនដែលរងការប៉ះពាល់ខ្លាំងជាងគេដោយសារផលប៉ះពាល់ពីអាកាសធាតុ មានដូចជាសហគមន៍ដែលមានចំណូលទាប សហគមន៍ដែលមិនមែនជាជនជាតិស្បែកស អ្នកជួបបញ្ហាគ្មានផ្ទះសម្បែង មនុស្សចាស់ និងជនពិការ។
- កសាងប្រព័ន្ធសម្របសម្រួលនៅទូទាំងទីភ្នាក់ងាររបស់ខោនធី ព្រមទាំងជាមួយដៃគូក្នុងតំបន់ និងសហគមន៍ដើម្បីសម្រេចបានគោលដៅរួម។

# របៀបដែលយើងរៀបរចនាសម្ព័ន្ធផែនការ

ផែនការនេះបែងចែកជាវិស័យសកម្មភាពចំនួនប្រាំមួយ ដែលវិស័យនីមួយៗដើរតួយ៉ាងសំខាន់ក្នុងការសម្រេចគោលដៅរបស់យើង៖ បរិស្ថានដែលត្រូវបានបង្កើតឡើង ភាពធន់របស់សហគមន៍ វិបុលភាព និងសេដ្ឋកិច្ចបៃតង ការគ្រប់គ្រងសម្ភារៈប្រកបដោយនិរន្តរភាព ការដឹកជញ្ជូន និងអភិបាលកិច្ច និងភាពជាអ្នកដឹកនាំផ្នែកអាកាសធាតុ។ វិស័យសកម្មភាពនីមួយៗមាន៖

- និទានកថាណែនាំដើម្បីតម្រង់ទិសអ្នកអាន។
- ផ្នែករងចំនួនពីរទៅបួន ដែលមានក្រុមនៃវិធានការដែលបានតម្រែតម្រង់ហើយ។
- វិធានការសរុបចំនួនប្រាំពីរទៅ 12 ដែលវិធានការនីមួយៗមានតារាងបង្ហាញពីសកម្មភាព ឬ "វិធានការរង" ដើម្បីសម្រេចគោលដៅនៃវិធានការនោះ។

សម្រាប់វិធានការនីមួយៗ តារាងមានរាយនូវវិធានការរងទាំងអស់ ក្រសួងសំខាន់ៗដែលអនុវត្តវិធានការទាំងនោះ អត្ថប្រយោជន៍សកម្មភាពខាងអាកាសធាតុជាអាទិភាពរបស់ពួកវា និងអត្ថប្រយោជន៍រួមណាមួយ ព្រមទាំងចំនួនទឹកប្រាក់វិនិយោគដែលត្រូវការ។ រូបតំណាងដែលប្រើនៅក្នុងតារាងទាំងនេះមានពិពណ៌នានៅក្នុងទិដ្ឋភាពទូទៅនៃផែនការ។

## វិស័យសកម្មភាព

### បរិស្ថានដែលត្រូវបានបង្កើតឡើង (BE)

គ្រប់គ្រងអគារ ហេដ្ឋារចនាសម្ព័ន្ធ និងទេសភាពរបស់ខោនធី ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបង្កើនភាពធន់នឹងអាកាសធាតុនៃគម្រោងក្នុងខោនធីរបស់យើង។

### ភាពធន់នៃសហគមន៍ (CR)

បង្កើនភាពធន់ និងការត្រៀមលក្ខណៈនៃសហគមន៍ដែលយើងបម្រើដើម្បីការពារទប់ទល់នឹងផលប៉ះពាល់នៃអាកាសធាតុដូចជា រលកកម្តៅ ភ្លើងឆេះព្រៃ ឬទឹកជំនន់។

### វិបុលភាព និងសេដ្ឋកិច្ចបៃតង (GEP)

វិនិយោគលើយុទ្ធសាស្ត្រឈ្នះ-ឈ្នះ ដែលកាត់បន្ថយស្លាកស្នាមបរិស្ថានរបស់ខោនធី ស្របពេលដែលធ្វើឱ្យសេដ្ឋកិច្ចក្នុងមូលដ្ឋានលូតលាស់ ព្រមទាំងបង្កើតការងារ និងឱកាសខាងសេដ្ឋកិច្ចសម្រាប់ប្រជាជនមូលដ្ឋាន។

### ការគ្រប់គ្រងសម្ភារៈប្រកបដោយនិរន្តរភាព (SMM)

អនុវត្តដំណោះស្រាយពីថ្នាក់លើ និងគោលការណ៍សេដ្ឋកិច្ចវិលជុំ ដើម្បីកាត់បន្ថយបរិមាណសំណល់ដែលកើតពីប្រតិបត្តិការក្នុងខោនធី។

### ការដឹកជញ្ជូន (T)

កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រតិបត្តិការនៃក្រុមយានជំនិះរបស់ខោនធី និងការធ្វើដំណើរទៅមកពីកន្លែងធ្វើការរបស់និយោជិត។

### អភិបាលកិច្ច និងភាពជាអ្នកដឹកនាំផ្នែកអាកាសធាតុ (CLG)

ពង្រីកសកម្មភាពតាមរយៈទំនាក់ទំនងខាងក្រៅ កាត់បន្ថយហានិភ័យអាកាសធាតុនៅក្នុងការវិនិយោគ និងផ្តល់មូលដ្ឋានគ្រឹះសម្រាប់សកម្មភាពធ្វើផែនការផ្សេងៗទៀតតាមរយៈ ការបង្កើតរចនាសម្ព័ន្ធការអនុវត្ត ការលើកឡើងអំពីវិធីសាស្ត្រកាត់ទទឹងដូចជាការធ្វើការពីចម្ងាយជាដើម និងការគាំទ្រនិយោជិតដើម្បីត្រៀមខ្លួនសម្រាប់ផលប៉ះពាល់ពីអាកាសធាតុ។

## បរិស្ថានដែលត្រូវបានបង្កើតឡើង (BE)



*ស្នាដៃ៖ ដេវីដ វ៉េកលី ។ ស្នាដៃសិល្បៈមនៅក្នុងបណ្ណាល័យ បណ្ណាល័យខាស្រ្តូ វ៉ាលលី របស់ខោនធី ធ្វើដោយ Jos Sances ជាផ្នែកមួយនៃកម្រងសិល្បៈខោនធី អាឡាមេដា។ ស្នាដៃសិល្បៈមនៅក្នុងបណ្ណាល័យ បណ្ណាល័យខាស្រ្តូ វ៉ាលលី របស់ខោនធី ធ្វើដោយ ចូសសាន់សេ ជាផ្នែកមួយនៃកម្រងសិល្បៈខោនធី អាឡាមេដា ។*

ខោនធី អាឡាមេដា កាន់កាប់ ឬជួលក្រុមអគារប្រហែល 8.7 លានហ្វីតការ៉េ និងរក្សាហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅក្នុងតំបន់មិនរួមបញ្ចូល។ ការសម្រេចគោលដៅអាកាសធាតុរបស់យើងនឹងទាមទារឱ្យយើងកាត់បន្ថយការបំភាយឧស្ម័នកាបូនិចទៅលើថាមពលតាមរយៈការប្តូរពីឧស្ម័នធម្មជាតិទៅឧបករណ៍ដើរដោយអគ្គិសនីនៅក្នុងអគាររបស់យើង។ ធ្វើបែបនេះនឹងលុបបំបាត់ការដុតឥន្ធនៈផូស៊ីលនៅនឹងកន្លែង និងជំនួសវិញនូវឧបករណ៍ដែលប្រើថាមពលដោយថាមពលកកើតឡើងវិញ។ យើងគ្រោងរចនា និងសាងសង់អគារថ្មីៗ និងការជួសជុលកែលម្អធំៗដើម្បីឱ្យមានការបំភាយកាបូនកម្រិតសូន្យ បង្កើនជាអតិបរមានូវប្រសិទ្ធភាពថាមពល និងរួមបញ្ចូលធនធានថាមពលដែលបានចែកចាយ។ យើងក៏នឹងកាត់បន្ថយប្រភពនៃការបំភាយឧស្ម័នផ្ទះកញ្ចក់តាមរយៈការដាក់ទីតាំងអគារថ្មីនៅជិតកន្លែងដឹកជញ្ជូនសាធារណៈ ការប្រើទីលំហប្រកបដោយប្រសិទ្ធភាព ការជ្រើសរើសឧបករណ៍ដែលប្រើសារធាតុត្រជាក់មានសក្តានុពលធ្វើឱ្យមានកំណើនកម្តៅផែនដីទាប និងការជ្រើសរើសសម្ភារៈសំណង់ ការអនុវត្ត និងការរចនាដែលប្រើបំភាយកាបូនតិច។ យើងគ្រោងនឹងបំពេញបន្ថែមកិច្ចខិតខំប្រឹងប្រែងទាំងនេះតាមរយៈការស្រូបកាបូនតាមរយៈការជ្រើសរើសការគ្រប់គ្រងទេសភាពឆ្លាតវៃ។

ដោយសារអគារនានារបស់ខោនធីផ្តល់សេវាកម្មចាំបាច់ជាច្រើនដល់ប្រជាជនមូលដ្ឋាន យើងនឹងអនុវត្តជំហាននានាដើម្បីធ្វើឱ្យបរិស្ថានដែលត្រូវបានបង្កើតឡើងរបស់យើងមានភាពធន់នឹងហានិភ័យអាកាសធាតុ ដូចជាការបន្ថែមកន្លែងផ្ទុកអាគុយនៅតាមអគារដើម្បីឱ្យអគារអាចដំណើរការបាននៅពេលដាច់ភ្លើង។

### វិធានការ បរិស្ថានដែលត្រូវបានបង្កើតឡើង

**ការគ្រប់គ្រងកម្មវិធី**

BE 1៖ ការបង្កើតគោលនយោបាយ និងការគ្រប់គ្រងកម្មវិធី

**កាត់បន្ថយការបំភាយឧស្ម័ន**

BE 2 កាត់បន្ថយការបំភាយឧស្ម័នកាបូនិចចំពោះសំណង់ថ្មី

BE 3៖ កាត់បន្ថយការបំភាយឧស្ម័នកាបូនិចលើគម្រោងដែលមានស្រាប់

BE 4៖ ប្រតិបត្តិការកាបូនតិច

BE 5៖ ការជួលបៃតង

**កាត់បន្ថយ និងបំបាត់កាបូន**

BE 6៖ បង្កើនប្រសិទ្ធភាពការរៀបចំផែនការលើទីតាំង និងលំហដើម្បីប្រសិទ្ធភាពកាបូន

BE 7៖ កាត់បន្ថយឱ្យដល់កម្រិតអប្បបរមានូវការបំភាយកាបូន ក្នុងវដ្តជីវិតនៃសម្ភារៈសាងសង់ និងសំណង់

BE 8៖ ការស្រូបយកកាបូន

**រៀបចំគម្រោង**

BE 9៖ ភាពធន់នឹងអាកាសធាតុសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងអគារ

BE 10៖ គ្រប់គ្រងដីសម្រាប់ ភាពធន់នឹងអាកាសធាតុ

BE 11៖ ការរក្សាទុកទឹក និងការត្រៀមលក្ខណៈសម្រាប់គ្រោះរាំងស្ងួត

## ភាពធន់នៃសហគមន៍ (CR)

ផ្នែកដ៏សំខាន់នៃបេសកកម្មរបស់ខោនធីគឺផ្តល់សេវាកម្មដល់សហគមន៍របស់យើង ដែលមានដូចជាសេវាកម្មសង្គម សុខភាព សុវត្ថិភាពសាធារណៈ និងសេវាកម្មហេដ្ឋារចនាសម្ព័ន្ធ។ ដើម្បីបន្តផ្តល់សេវាកម្មចាំបាច់នានា យើងនឹងរៀបចំប្រព័ន្ធគ្រប់គ្រងគ្រាអាសន្នរបស់ខោនធី និងកម្មវិធីសុខភាពនិងសង្គមនានា ដើម្បីធានាថាប្រព័ន្ធ និងកម្មវិធីទាំងនោះអាចដំណើរការបានក្នុងពេលមានផលប៉ះពាល់នៃអាកាសធាតុ។



សេវាកម្មមួយក្នុងចំណោមសេវាកម្មចាំបាច់គឺដើម្បីជួយសហគមន៍របស់យើងឱ្យកាន់តែមានភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចជាភ្លើងឆេះព្រៃ ការកើននីវ៉ូទឹកសមុទ្រ និងការប្រែប្រួលលំនាំទឹកភ្លៀង។ យើងនឹងគាំទ្រសហគមន៍របស់យើងតាមរយៈការបង្កើតធនធានដែលអាចប្រើបាន និងអគារសម្រាប់ភាពធន់ និងការគាំទ្រសុខភាពផ្លូវចិត្តរបស់ប្រជាជនមូលដ្ឋាន។ យើងនឹងជួយសហគមន៍របស់យើងរៀបចំដោយការចែករំលែកព័ត៌មានដែលពាក់ព័ន្ធជាមូលដ្ឋានអំពីគ្រោះអាសន្នទាក់ទងនឹងអាកាសធាតុ និងវិធីដែលពួកគេអាចការពារខ្លួន។ ការផ្សព្វផ្សាយដល់មូលដ្ឋាននឹងសង្កត់ធ្ងន់លើការចុះទៅដល់ប្រជាជនមូលដ្ឋានដែលរងគ្រោះខ្លាំងជាងគេដោយសារការប្រែប្រួលអាកាសធាតុ និងសហគមន៍ដែលពីមុននិងឥឡូវមិនសូវមានគេទៅដល់។

### វិធានការភាពធន់នៃសហគមន៍

**ការត្រៀមលក្ខណៈប្រព័ន្ធខោនធី**

CR 1៖ ការគ្រប់គ្រងគ្រាអាសន្នដែលមានភាពធន់

CR 2៖ ការផ្សព្វផ្សាយដល់មូលដ្ឋាន និងទំនាក់ទំនង

CR 3៖ សេវាកម្មសង្គម និងសុខភាពដែលមានភាពធន់

**ការត្រៀមលក្ខណៈសហគមន៍**

CR 4៖ ធនធានសម្រាប់ភាពធន់

CR 5៖ ភាពធន់ដែលផ្អែកលើទីកន្លែង

CR 6៖ សុខភាពផ្លូវចិត្ត និងភាពធន់

**ការសម្របសម្រួលខាងក្រៅ**

CR 7៖ ភាពធន់ក្នុងតំបន់

CR 8៖ ការចូលរួមនៃសហគមន៍ដែលមានសមធម៌

**ការត្រៀមខ្លួនសម្រាប់ផលប៉ះពាល់ជាក់លាក់**

CR 9៖ កាត់បន្ថយហានិភ័យអគ្គិភ័យ

CR 10៖ ការគ្រប់គ្រងជំនន់

## វិបុលភាព និងសេដ្ឋកិច្ចបៃតង (GEP)

ក្នុងនាមជារដ្ឋាភិបាលខោនធី យើងចង់ធានាថាសហគមន៍ និងអាជីវកម្មក្នុងមូលដ្ឋានរបស់យើងមានផលប្រយោជន៍រួមពីការប្តូរទៅសេដ្ឋកិច្ចបៃតងដែលមានបរិយាប័នសង្គមនិងកាបូនតិច។ ការមានការងារ មានផ្ទះ និងមានធនធានដើម្បីការពារខ្លួន គឺជួយមនុស្សឱ្យមានភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ផ្នែកនេះនៃផែនការរួមមានយុទ្ធសាស្រ្តចម្រុះនៅត្រង់ចំណុចប្រសព្វនៃអេកូឡូស៊ីសេដ្ឋកិច្ច និងសមធម៌។



យើងនឹងជួយអ្នកផ្តល់សេវាកម្ម និងអ្នកលក់នានានៅក្នុងខោនធីនាបច្ចុប្បន្ន និងពេលអនាគតឱ្យធ្វើប្រតិបត្តិការប្រកបដោយនិរន្តរភាព ជួយអតិថិជនរបស់ពួកគេត្រៀមខ្លួនបានល្អជាងមុន និងមានសុវត្ថិភាពពីផលប៉ះពាល់នៃអាកាសធាតុ។ យើងនឹងគាំទ្រអ្នកលក់ និងក្រសួងនានារបស់ខោនធីក្នុងការប្រមូលអាហារ និងការកាត់បន្ថយសំណល់អាហារ និងនៅក្នុងការស្វែងរកជម្រើសអាហារដែលបំភាយកាបូនតិច។ យើងក៏នឹងគាំទ្រកសិកររបស់ខោនធី និងសេដ្ឋកិច្ចចំណីអាហារប្រកបដោយនិរន្តរភាពរបស់មូលដ្ឋានតាមរយៈការប្រើប្រាស់ដី និងកម្មវិធីនានាដែលមានមូលដ្ឋាននៅក្នុងភូមិសង្កាត់ និងរួមបញ្ចូលគោលការណ៍ សេដ្ឋកិច្ចវិលជុំ នៅទូទាំងខោនធី និងតំបន់។

ដើម្បីធានាថាសេដ្ឋកិច្ចបៃតងផ្តល់ផលប្រយោជន៍ដល់ប្រជាជនមូលដ្ឋាន យើងគ្រោងនឹងពង្រីកភាពជាដៃគូរបស់យើងជាមួយនឹងកម្មវិធីអភិវឌ្ឍន៍កម្លាំងពលកម្មក្នុងមូលដ្ឋានដើម្បីគាំទ្រកម្លាំងពលកម្មដែលមានការត្រៀមលក្ខណៈ បានបណ្តុះបណ្តាល និងមានភាពសម្បូរបែប។

### សេដ្ឋកិច្ចបៃតង និងវិធានការវិបុលភាព

**លទ្ធកម្ម**

GEP 1៖ ភាពធន់ និងនិរន្តរភាពអ្នកលក់

GEP 2៖ ការធ្វើកិច្ចសន្យាជាមួយអង្គការមិនរកប្រាក់ចំណេញខ្នាតតូច

**កម្លាំងពលកម្ម**

GEP 3៖ ការជួលអ្នកធ្វើការសម្រាប់គម្រោងប្រើដើមទុនច្រើនដែលទាក់ទងនឹងអាកាសធាតុ

GEP 4៖ ការលើកកម្ពស់ការងារបៃតង

GEP 5៖ ការបង្កើនកម្លាំងពលកម្មខាងអាកាសធាតុនៅខោនធី Alameda

**ការគ្រប់គ្រងសម្ភារៈ**

GEP 6៖ ការអភិវឌ្ឍសេដ្ឋកិច្ចវិលជុំក្នុងតំបន់

GEP 7៖ ការពង្រីកការប្រមូលអាហារដែលអាចហូបបាន

GEP 8៖ ការរកប្រភពអាហារដែលប្រើកាបូនតិចជួយឱ្យសុខភាពកាន់តែល្អ

GEP 9៖ សេដ្ឋកិច្ចអាហារវិលជុំដែលបានរួមបញ្ចូល

## ការគ្រប់គ្រងសម្ភារៈប្រកបដោយនិរន្តរភាព (SMM)



*រូបថតអំពីបណ្ណាល័យឱ្យខ្ចីឧបករណ៍ដោយ ដេវីដ វ៉េកលី, អនុញ្ញាតដោយបណ្ណាល័យ បណ្ណាល័យសាធារណៈប៊ែឃើលី*

យើងនឹងរួមបញ្ចូលគំនិតផ្ដួចផ្ដើមការកាត់បន្ថយសំណល់ខ្សែខាងលើនៅក្នុងប្រតិបត្តិការរបស់យើង និងងាកចេញពីការអនុវត្តផ្អែកលើការបោះចោល និងលក្ខណៈខ្សែបន្ទាត់ត្រង់ ដើម្បីកាត់បន្ថយការបំភាយពីការទាញយក ការផលិតបង្កើត ការដឹកជញ្ជូន និងការចែកចាយផលិតផលថ្មីៗ។ វិស័យផ្ដោតរួមមានការផ្ដល់ជំនួយបច្ចេកទេស និងការផ្សព្វផ្សាយតាមកម្មវិធី និងគម្រោងនានាដើម្បីកាត់បន្ថយសំណល់ដែលខោនធីបានបង្កើត។ វាតម្រូវឱ្យមានការអប់រំបុគ្គលិក ភាគីពាក់ព័ន្ធ និងសមាជិកសហគមន៍ដើម្បីឱ្យមនុស្សកាន់តែច្រើនចូលរួមក្នុងកម្មវិធីកាត់បន្ថយសំណល់។ ការផ្ដោតមួយទៀតគឺការគាំទ្រសេដ្ឋកិច្ចវិលជុំ ដើម្បីរក្សាទំនិញនិងសម្ភារៈដែលកំពុងប្រើឱ្យបានយូរឱ្យអស់លទ្ធភាព តាមរយៈការពង្រីកកិច្ចខិតខំប្រឹងប្រែងជួសជុល និងប្រើឡើងវិញជាលក្ខណៈផ្ទៃក្នុង ការស្វែងរកមធ្យោបាយផ្សេងចំពោះការទិញថ្មីៗ ការអនុវត្តការគាំទ្រគោលនយោបាយនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងការបង្កើតយុទ្ធសាស្ត្រសម្រាប់ការរៀបចំការប្រជុំ និងព្រឹត្តិការណ៍របស់ខោនធីដែលគ្មានសំណល់។

នៅក្នុងលទ្ធកម្ម យើងនឹងពង្រឹងគោលនយោបាយនៃការទិញ ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាននៃទំនិញអាទិភាពខ្ពស់របស់ខោនធីឱ្យដល់កម្រិតអប្បបរមា ដូចជាបច្ចេកវិទ្យានិងគ្រឿងសង្ហារិម និងការប្រើកម្លាំងនៃការទិញរបស់យើងដើម្បីជួយទីផ្សារលើការរចនា និងការផលិត។ ចុងក្រោយ យើងនឹងលើកកម្ពស់គោលការណ៍សេដ្ឋកិច្ចវិលជុំនៅក្នុងបរិស្ថានដែលត្រូវបានបង្កើតឡើងតាមរយៈការយកមកវិញនូវសម្ភារៈសំណង់ និងទំនិញជាប់បានយូរពីសំណង់អគារដែលគេបំផ្លាញចោល និងការប្រើប្រាស់ពួកវានៅក្នុងអគារថ្មី និងនៅក្នុងការជួសជុលកែលម្អ។

### វិធានការការគ្រប់គ្រងសម្ភារៈប្រកបដោយនិរន្តរភាព

**ជំនួយបច្ចេកទេស និងការផ្សព្វផ្សាយដល់មូលដ្ឋាន**

SMM 1៖ ការអនុវត្តកម្មវិធីប្រតិបត្តិការ

SMM 2៖ យុទ្ធសាស្ត្រក្នុងការអប់រំ និងការផ្សព្វផ្សាយដល់មូលដ្ឋាន

**សេដ្ឋកិច្ចវិលជុំ**

SMM 3៖ គោលនយោបាយឋានានុក្រមប្រើឡើងវិញ

SMM 4៖ ការអនុវត្តការជួសជុល និងការប្រើឡើងវិញ

SMM 5៖ ព្រឹត្តិការណ៍គ្មានកាកសំណល់

**លទ្ធកម្ម**

SMM 6៖ ការពង្រឹងគោលនយោបាយទិញ

SMM 7៖ ការសាងសង់ និងការវាយកម្ទេច

## ការដឹកជញ្ជូន (T)

ការធ្វើដំណើររបស់និយោជិតខោនធីទៅមកពីកន្លែងធ្វើការ និងក្នុងពេលធ្វើការរួមចំណែកដល់ការបំភាយឧស្ម័នពីប្រតិបត្តិការរបស់យើងមួយផ្នែកធំ។ ការគាំទ្រចំពោះការងារពីចម្ងាយគឺស្ថិតក្នុងវិស័យសកម្មភាពខាងអភិបាលកិច្ច និងភាពជាអ្នកដឹកនាំផ្នែកអាកាសធាតុ។ ការដឹកជញ្ជូនប្រកបដោយចីរភាពសម្រាប់និយោជិតទៅកន្លែងធ្វើការ និងក្នុងពេលធ្វើការ ត្រូវបានគូសបញ្ជាក់នៅក្នុងវិស័យសកម្មភាពនេះ។ យើងត្រូវធ្វើឱ្យក្រុមយានរបស់ខោនធីជាក្រុមយានបៃតង។ យើងមានផែនការធ្វើការនេះដោយបញ្ចូលអគ្គិសនីឱ្យយានយន្តស្របតាមបទបញ្ជាស្ដីពីយានយន្តគ្មានការបំភាយឧស្ម័ននៅឆ្នាំ 2035 របស់រដ្ឋ និងការកែលម្អប្រសិទ្ធភាពរបស់ក្រុមយាន។ ការណ៍នេះរួមមានទាំងប្រសិទ្ធភាពនៃយានយន្តរបស់ក្រសួងសាធារណការ ដែលច្រើនតែមានទម្ងន់ធ្ងន់ និងដុតប្រេងម៉ាស៊ូត។ យើងក៏ត្រូវគាំទ្រដល់ការធ្វើដំណើរទៅមកពីកន្លែងធ្វើការឱ្យស្អាតផងដែរ។ ផ្នែកនេះណែនាំអំពីវិធីផ្ដល់គ្រឿងលើកទឹកចិត្ត និងគាំទ្រនិយោជិតឱ្យធ្វើដំណើរតាមមធ្យោបាយដែលកាន់តែមានប្រសិទ្ធភាពជាងការបើកបរតែម្យ៉ាង ដូចជាតាមរយៈការពង្រីកសេវាកម្មកង់ និងសេវាកម្មដឹកទៅមក។



### វិធានការដឹកជញ្ជូន
### ដឹកជញ្ជូន

### ក្រុមយានជំនិះបៃតង

- T 1៖ ការផ្លាស់ប្ដូរក្រុមយានជំនិះ
- T 2៖ ការគ្រប់គ្រងក្រុមយានជំនិះ
- T 3៖ ការអនុវត្តនៃក្រុមយានជំនិះប្រកបដោយចីរភាព
- T 4៖ ក្រុមយានជំនិះនៃទីភ្នាក់ងារការងារសាធារណៈ

### ការធ្វើដំណើរទៅមកពីកន្លែងធ្វើការដោយនិយោជិត

- T 5៖ ការលើកទឹកចិត្តឱ្យធ្វើដំណើរទៅមកពីកន្លែងធ្វើការឱ្យស្អាត
- T 6៖ គោលនយោបាយចំណតឆ្លាតវៃ
- T 7៖ សេវាកម្មកង់ និងដឹកទៅមក
- T 8៖ យានជំនិះតូចៗ
- T 9៖ កម្មវិធីសំបុត្រអនុញ្ញាតធ្វើដំណើរឆ្លងកាត់

## អភិបាលកិច្ច និងភាពជាអ្នកដឹកនាំផ្នែកអាកាសធាតុ (CLG)



ការបំប្លែងផែនការពីពាក្យពេចន៍ទៅជាសកម្មភាពត្រូវការមនុស្សដឹកនាំវា និងត្រូវការគោលនយោបាយជាមូលដ្ឋានដ៏មានប្រសិទ្ធភាព។ វិស័យសកម្មភាពខាងអភិបាលកិច្ច និងភាពជាអ្នកដឹកនាំផ្នែកអាកាសធាតុ រួមមានចំណុចផ្តោតបួនប្រភេទ៖ ការតស៊ូមតិ និងការផ្សព្វផ្សាយដល់មូលដ្ឋានដើម្បីជំរុញសកម្មភាពខាងអាកាសធាតុ ក្របខណ្ឌប្រតិបត្តិការសម្រាប់ការអនុវត្តផែនការ ការគាំទ្រដល់ការត្រៀមលក្ខណៈរបស់និយោជិត និងយុទ្ធសាស្ត្រហិរញ្ញវត្ថុ។ សកម្មភាពតស៊ូមតិ និងសកម្មភាពផ្សព្វផ្សាយដល់មូលដ្ឋាន រួមមានផែនការតស៊ូមតិឱ្យមានការគាំទ្រពីរដ្ឋ និងសហព័ន្ធ និងផែនការចែករំលែកនូវអ្វីៗដែលយើងរៀនដល់សហគមន៍របស់យើង និងរដ្ឋាភិបាលផ្សេងៗនៅក្នុងតំបន់របស់យើង។ រចនាសម្ព័ន្ធគណនេយ្យភាពផ្ទៃក្នុងដើម្បីធានាឱ្យសកម្មភាពអាចធ្វើទៅបាន ក៏ដូចជាគោលដៅ និងការវាស់វែងដើម្បីវាស់មើលថាតើគោលដៅទាំងនោះបានសម្រេចឬអត់ គឺសុទ្ធតែសំខាន់។ យើងនឹងធ្វើសកម្មភាពខាងភាពជាអ្នកដឹកនាំដែលដឹកនាំយើងទៅរកការបន្សាំបកាបូន តាំងពីការកាត់បន្ថយការធ្វើដំណើរទៅមកពីកន្លែងធ្វើការរបស់និយោជិតតាមរយៈការធ្វើការពីចម្ងាយ រហូតដល់ការចងចាំនូវគោលដៅខាងអាកាសធាតុរបស់យើងក្នុងចិត្ត នៅពេលដែលយើងអភិវឌ្ឍថវិកា បង្កើតផែនការ និងអភិវឌ្ឍចក្ខុវិស័យរបស់យើង។ ដើម្បីទទួលបានជោគជ័យ ទីភ្នាក់ងារនានាក៏នឹងត្រូវការធនធានបច្ចេកទេសផងដែរ តាំងពីអ្នកសរសេរស្នើសុំជំនួយ ឬការបណ្តុះបណ្តាលអំពីការសរសេរស្នើសុំជំនួយ រហូតដល់អ្នករួមការងារ និងអ្នកប្រឹក្សាប្រចាំការតាមការហៅទូរសព្ទ។

ដើម្បីបម្រើសហគមន៍បានល្អបំផុត និយោជិតរបស់យើងត្រូវមានសុវត្ថិភាពពីផលប៉ះពាល់នៃអាកាសធាតុ ហើយមានធនធានដើម្បីគាំទ្រដល់សុខភាពផ្លូវចិត្តរបស់ពួកគេ។ ដើម្បីធ្វើសកម្មភាពឱ្យបានជាប់លាប់ និងមានមូលនិធិដែលយើងនឹងត្រូវការ យើងត្រូវតែធានាថា ការវិនិយោគខាងហិរញ្ញវត្ថុរបស់យើង គាំទ្រដល់សកម្មភាពខាងសុខភាពអាកាសធាតុ និងលើកឡើងនូវវិធីសាស្ត្រថ្មីៗដើម្បីទំនុកបម្រុងមូលនិធិដល់សកម្មភាពខាងអាកាសធាតុរបស់យើង និងទ្រទ្រង់ភាពធន់។

### វិធានការអភិបាលកិច្ច និងភាពជាអ្នកដឹកនាំផ្នែកអាកាសធាតុ

**ការតស៊ូមតិ និងការផ្សព្វផ្សាយដល់មូលដ្ឋាន**

CLG 1៖ ការតស៊ូមតិផ្នែកនីតិកម្ម

CLG 2៖ ការចែករំលែកខាងក្រៅ

CLG 3៖ ការផ្សព្វផ្សាយជាសាធារណៈ

**ការអនុវត្តផែនការ**

CLG 4៖ ចក្ខុវិស័យ និងផែនការយុទ្ធសាស្ត្រ

CLG 5៖ រចនាសម្ព័ន្ធនៃការអនុវត្ត

CLG 6៖ ធនធាននៃការអនុវត្ត

CLG 7៖ គោលដៅ

**ការត្រៀមលក្ខណៈរបស់និយោជិត**

CLG 8៖ ការគាំទ្រការងារពីចម្ងាយ

CLG 9៖ សុវត្ថិភាពនិយោជិត

CLG 10៖ ការបំពាក់បំប៉ននិយោជិតដើម្បីឆ្លើយតបនឹងអាកាសធាតុ

**យុទ្ធសាស្ត្រហិរញ្ញវត្ថុ**

CLG 11៖ ការវិនិយោគ

CLG 12៖ វិធីសាស្ត្រផ្គត់ផ្គង់មូលនិធិ

## របៀបដែលយើងនឹងអនុវត្ត និងវាយតម្លៃផែនការ

ផែនការនេះត្រូវបានរៀបចំឡើងដើម្បីធ្វើជាផែនទីដែលអាចបត់បែនបាន និងមិនមែនជាបញ្ជីផ្ទៀងផ្ទាត់ទេ។ ក្នុងពេលដែលយើងវាយឈ្មោះទីភ្នាក់ងារសំខាន់ៗដែលអនុវត្តសម្រាប់វិធានការរងឬសកម្មភាពនីមួយៗ យើងរំពឹងថា ការបែងចែករបស់ខោនធីនឹងផ្តល់អាទិភាពដល់សកម្មភាពដែលពួកគេដោះស្រាយដោយផ្អែកលើកាលៈទេសៈ តម្រូវការ មូលនិធិ និងវិសាលភាពរបស់ពួកគេ។ យើងមិនរំពឹងថា គ្រប់សកម្មភាពទាំងអស់នៅក្នុងផែនការនេះសុទ្ធតែនឹងដើរទៅមុខនោះទេ។ ទីភ្នាក់ងារនានាត្រូវបានស្វាគមន៍ឲ្យបង្កើតលសកម្មភាពផ្សេងទៀត ឬសកម្មភាពបន្ថែមដើម្បីសម្រេចបាននូវគោលដៅនៃវិធានការ និងគោលដៅរួម។

ក្រុមការងារវិស័យសកម្មភាព និងគម្រោង នឹងបង្កើតហើយតាមដានការវាស់វែងដើម្បីយល់ថា តើគោលដៅវិធានការសម្រេចបានឬអត់ និងសម្រេចដោយរបៀបណា។ យើងប្តេជ្ញារក្សាគណនេយ្យភាព និងតម្លាភាព ហើយយើងនឹងផ្តល់ព័ត៌មានបច្ចុប្បន្នភាពប្រចាំឆ្នាំដល់ក្រុមប្រឹក្សាប្រធានយ និងសាធារណជន។

## សន្និដ្ឋាន

ផែនការសកម្មភាពខាងអាកាសធាតុសម្រាប់សេវាកម្ម និងប្រតិបត្តិការរបស់រដ្ឋាភិបាលនេះតំណាងឱ្យអត្ថន័យពង្រីកនៃសកម្មភាពខាងអាកាសធាតុ ដែលរួមមានវិបុលភាពប្រកបដោយចីរភាពនៅក្នុងសហគមន៍របស់យើង គោលដៅជាមូលដ្ឋានក្នុងការជំរុញសមធម៌ ព្រមទាំងការត្រៀមលក្ខណៈ និងសកម្មភាពឆ្លើយតបដើម្បីការពារប្រជាជនមូលដ្ឋានរបស់យើងកុំឱ្យរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ។ ការប្រើរយៈពេលកាន់តែខ្លីក្នុងការអនុវត្តផែនការនេះ អាចឱ្យខោនធីមានភាពរហ័សរហួន ហើយផ្លាស់ប្តូរសកម្មភាពជាអាទិភាពនានារបស់យើងស្របពេលដែលរក្សាបាននូវគោលដៅតាមមហិច្ឆតា និងរក្សាបាននូវការយល់ដឹងដ៏រឹងមាំនេះអំពីសកម្មភាពខាងអាកាសធាតុ។

បុគ្គលិកខោនធីរាប់រយនាក់ និងសមាជិកសហគមន៍រាប់ពាន់នាក់បានរួមចំណែកផ្តល់គំនិត គោលដៅ និងការត្រួតពិនិត្យឡើងវិញយ៉ាងប្រុងប្រយ័ត្នចំពោះផែនការនេះ។ ជាមួយគ្នានេះដែរ ផែនការនេះនិងផែនការផ្សេងៗទៀតនៅក្នុងតំបន់ នឹងជួយរក្សាសហគមន៍របស់យើងឱ្យមានសុវត្ថិភាព ហើយរួមចំណែកដល់គោលដៅកាត់បន្ថយកាបូនថ្នាក់ជាតិនិងពិភពលោក ដើម្បីពន្យឺតដំណើការប្រែប្រួលអាកាសធាតុរបស់យើង។ យើងទន្ទឹងរង់ចាំក្នុងការធ្វើឱ្យផែនការនេះក្លាយជាការពិតរួមជាមួយអ្នកទាំងអស់គ្នា។